**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ៖ ..............................

ថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ភ្នំពេញ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៨

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ នៃគ.ជ.ប.ជ**
**ឯកឧត្តម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

**ជាទីគោរព**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីការចូលរួម និងលទ្ធផលនៃ កិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទៅ១០នៅទីក្រុង ប្រ៊ុសសែល ប្រទេសបែលហ្ស៊ិក កាលពីថ្ងៃទី១២-១៤ ខែមិនា ឆ្នាំ២០១៨។

**យោង ៖** លិខិតអញ្ជើញរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លេខ៨៨៣សអ.កបទ.សអ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨។

- លិខិតសំណើសុំកែសម្រួល និងបន្ថែមសមាសភាពមន្ត្រីជាន់ខ្ពស់ ក្រសួងមហាផ្ទៃចំនួន៥រូប និងស្នើសុំកំណត់ទូតលើកលែងទិដ្ឋាការ ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-អឺរ៉ុបលើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលស្ស៊ិក លេខ៣០៥លស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៣ខែមិនា ឆ្នាំ២០១៨។

តបតាមកម្មវត្ថុនិងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** ស្តីពីការចូលរួម និងលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទៅ១០ ដែលបានប្រព្រឹត្តទៅនៅទីក្រុង ប្រ៊ុសសែល ប្រទេសបែលហ្ស៊ិក កាលពីថ្ងៃទី១២-១៤ ខែមិនា ឆ្នាំ២០១៨។ កិច្ចប្រជុំមានការចូលរួមពី ក្រុមការងារសហភាពអឺរ៉ុប និងគណៈប្រតិភូកម្ពុជាចំនួន ៤០រូប តំណាងឲ្យក្រសួង និងស្ថាប័ន របស់រាជរដ្ឋាភិបាលចំនួន ១៦ដឹកនាំដោយ ឯកឧត្តម **លុយ ដាវិត** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ តំណាងក្រសួងមហាផ្ទៃមាន៥រូបគឺ៖

| | |
|---|---|
| ១- ខ្ញុំបាទ **ឌី ច័ន្ទ្រផល** | រដ្ឋលេខាធិការ |
| ២- ឯកឧត្តម **ខ៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ |
| ៣- ឯកឧត្តម **ហ៊ុយ វណ្ណៈ** | អនុរដ្ឋលេខាធិការ |

៤- លោកជំទាវ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ.

៥- លោកស្រី **ខឹ ច័ន្ទ្រពុទ្ធិតា** ជំនួយការឯកឧត្តមរដ្ឋលេខាធិការ

កិច្ចប្រជុំបានដំណើរការអស់រយៈពេល៣ថ្ងៃ និងបែងចែកកិច្ចពិភាក្សាជា៣អនុក្រុម ដឹកនាំដោយសហប្រធានតំណាងឲ្យកម្ពុជាម្នាក់ និងសហភាពអឺរ៉ុបម្នាក់ នៅទីកន្លែងប្រជុំផ្សេងៗគ្នា គឺ៖

**ថ្ងៃទី១** - ១២មីនា២០១៨ - **<u>អនុក្រុមទី១ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍</u>** ដឹកនាំដោយតំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសហប្រធាន។ ក្នុងអនុក្រុមនេះ ឯកឧត្តម **ខ៉ាន់ ចំរើន** បានធ្វើបទអន្តរាគមន៍លើប្រធានបទ ***"ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"*** តំណាងឲ្យក្រសួងមហាផ្ទៃ ។

**ថ្ងៃទី២** - ១៣មីនា២០១៨ - មានកិច្ចប្រជុំជា២អនុក្រុម៖

- **<u>អនុក្រុមទី២ ស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ អភិបាលកិច្ច និងសិទ្ធិមនុស្ស</u>** ដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម **ខឹ ច័ន្ទ្រផល** តំណាងកម្ពុជា ជាសហប្រធាន។ ក្រោយការបង្ហាញពីបទអន្តរាគមន៍ ស្តីពី *"បច្ចុប្បន្នភាព ការខិតខំ និងវឌ្ឍនភាពលើការទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា"* ភាគីសហភាពអឺរ៉ុបបានអបអរដល់កិច្ចខិតខំប្រឹងប្រែងក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាដែលជាការងារមួយផ្នែកនៃការងារការពារសិទ្ធមនុស្ស និងដាក់ជាប្រធានបទសម្រាប់កិច្ចប្រជុំណាមួយលើកក្រោយ។ ប៉ុន្តែបានស្នើឲ្យរាជរដ្ឋាភិបាល ខិតខំដោះស្រាយបញ្ចប់ករណីវិវាទដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅដែលនៅសេសសល់(សមត្ថកិច្ចក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងពាណិជ្ជកម្ម)។ ភាគីសហភាពអឺរ៉ុបបានលើកឡើងពីការសម្រេចចិត្តមិនផ្តល់ថវិកា និងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតខាងមុខ បើលក្ខខណ្ឌខាងលើមិនមានដំណោះស្រាយ។

  ក្នុងកិច្ចប្រជុំអនុក្រុមនេះ ប្រតិភូតំណាងក្រសួងមហាផ្ទៃ បានធ្វើបទអន្តរាគមន៍ដូចខាងក្រោម៖

  ១- ខ្ញុំបាទ **ខឹ ច័ន្ទ្រផល** ជាសហប្រធានដឹកនាំកិច្ចប្រជុំអនុក្រុម និងបានធ្វើបទអន្តរាគមន៍លើប្រធានបទស្តីពី - ***"ស្ថានភាពសង្គមស៊ីវិល និងការអនុវត្តច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល"*** ។
  ២- ឯកឧត្តម **ហ៊ុយ វណ្ណៈ** បានធ្វើបទអន្តរាគមន៍ ស្តីពី ***"សិទ្ធិនយោបាយ និងលទ្ធិប្រជាធិបតេយ្យ"*** ។
  ៣- លោកជំទាវ **រ៉ែន សិរីលក្ខិណា** បានធ្វើបទអន្តរាគមន៍ ស្តីពី ***"បច្ចុប្បន្នភាព ការខិតខំ និងវឌ្ឍនភាពលើការទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា"***។

- **<u>អនុក្រុមទី៣ ស្តីពីពាណិជ្ជកម្ម និងវិនិយោគ</u>** ដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ជាសហប្រធាន និងបានពិនិត្យពិភាក្សាឡើងវិញពីស្ថានភាពពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-សហភាពអឺរ៉ុប និងបរិយាកាសវិនិយោគនៅកម្ពុជា។ ភាគីទាំងពីរបានដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការទទួលបានប្រព័ន្ធអនុគ្រោះពន្ធ "គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ" –"Everything But Arms (EBA)" ដែលបានជួយធ្វើឲ្យប្រសើរឡើងនូវពាណិជ្ជកម្មទ្វេភាគី និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជានាឆ្នាំកន្លងមកថ្មីៗនេះ។ ភាគីទាំងពីរក៏បានពិភាក្សាពីច្រកទីផ្សារសម្រាប់ក្រុមហ៊ុនអឺរ៉ុបនៅកម្ពុជា និងបានពិនិត្យឡើងវិញនូវការរីកចំរើន ពាណិជ្ជកម្មនៅក្នុងតំបន់ និងពហុភាគី។

**ថ្ងៃទី៣** - ១៤មីនា២០១៨ - **កិច្ចប្រជុំរួមរបស់គណៈកម្មាធិការចំរុះ** ដឹកនាំដោយ តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសហប្រធាន ។ ក្នុងកិច្ចប្រជុំរួមនេះ ក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំបាទ **ឌី ច័ន្ទ្រផល** បានធ្វើបទអន្តរាគមន៍លើប្រធានបទស្តីពី "*អភិបាលកិច្ច និងសិទ្ធិមនុស្ស*" - និង "*ស្ថានភាពទេសន្តប្រវេសន៍នៅកម្ពុជា*" ។

បន្ទាប់ពីកិច្ចប្រជុំរួមភាគីទាំងពីរ បានឯកភាពចេញនូវ "**សេចក្តីប្រកាសព័ត៌មានរួម**" នៃកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ ជាភាសាអង់គ្លេស និងបានបកប្រែជាភាសាខ្មែរ(ក្រៅផ្លូវការ) ដូចបានជូនភ្ជាប់មកជាមួយ។

ក្រុមការងារក្រសួងមហាផ្ទៃក៏បានធ្វើរបាយការណ៍ជម្រាបជូន សម្តេចក្រឡាហោម និងជូនទៅក្រសួងការបរទេសរួចរាល់កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើរបាយការណ៍ជូនទៅសម្តេចនាយកកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះសូម **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តមអគ្គលេខាធិការ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តមអគ្គលេខាធិការ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ ។

**អគ្គលេខាធិការរង**

នៃ_សិរីលក្ខិណា

**ឯកសារជូនភ្ជាប់៖**

- របាយការណ៍ជូនទៅសម្តេចនាយករដ្ឋមន្ត្រី
- របាយការណ៍ជូនទៅសម្តេចក្រឡាហោម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- Joint Press Release (ភាសាអង់គ្លេស និងភាសាខ្មែរ)
- សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការ Better Factories
- សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ លើបញ្ហាចំការអំពៅ

ចម្លងជូន៖

- ការិយាល័យលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គជបជ
- ការិយាល័យឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គលេខាធិការ គជបជ
- លេខាធិការដ្ឋាន គជបជ
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

លេខ: ៧២៨៣ សអ.កបទ.សអ

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**<u>កម្មវត្ថុ</u>**៖ លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ ថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្ស៊ិក។

ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ បានប្រព្រឹត្តទៅកាលពីថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្ស៊ិក។ គណៈប្រតិភូកម្ពុជាមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន១៦ ដឹកនាំដោយ ឯកឧត្តម លុយ ដាវិត រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំនេះ ដោយទទួលបាននូវលទ្ធផលសំខាន់ៗដូចតទៅ៖

I. <u>អំពីកិច្ចសហប្រតិបត្តិការ</u>

- សហភាពអឺរ៉ុបបានស្វាគមន៍ និងកោតសរសើរចំពោះការរីកចម្រើនរបស់ប្រទេសកម្ពុជា និងបានវាយតម្លៃចំពោះកិច្ចសហប្រតិបត្តិការល្អជាមួយកម្ពុជាជាងពីរទសវត្សរ៍មកនេះ។
- ភាគីទាំងពីរ ទទួលស្គាល់នូវការរួមចំណែកជាវិជ្ជមាននៃជំនួយរបស់សហភាពអឺរ៉ុប ក្នុងការគាំទ្រការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា និងការធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាតាមរយៈការគាំទ្រវិស័យអប់រំ ការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ច និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ភាគីទាំងពីរបានពិនិត្យមើលឡើងវិញអំពីការគាំទ្ររបស់សហភាពអឺរ៉ុប ចំពោះកម្មវិធីកំណែទម្រង់ និងផែនការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ សហភាពអឺរ៉ុប នឹងបន្តវាយតម្លៃកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគោលការណ៍ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh

- ភាគីទាំងពីរ ស្វាគមន៍សមិទ្ធផលរួមដែលសម្រេចបាន គិតតាំងពីកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី៩ កាលពីឆ្នាំ២០១៦ ដែលជាលទ្ធផលនៃការពន្លឿនការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីសូចនាករចម្រុះ (២០១៤-២០២០) ក្នុងគម្រោងទឹកប្រាក់ជំនួយសរុប ៤១០ លានអឺរ៉ូ ដែលក្នុងនោះអនុវត្តបាន ៦៧% ស្មើនឹង ២៧៤ លានអឺរ៉ូ គិតត្រឹមឆ្នាំ២០១៧។ តាមរយៈការពិនិត្យឡើងវិញនៃការអនុវត្តជំនួយរបស់ខ្លួន សហភាពអឺរ៉ុបបានព្រមព្រៀង ដោយបង្កើនជំនួយទៅលើកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំនួន ១០លានអឺរ៉ូ និងពង្រឹងការគាំទ្រការ វិនិយោគដោយផ្ទេរថវិកាចំនួន ១៥លានអឺរ៉ូ ទៅក្នុងកម្មវិធីសូចនាករក្របខ័ណ្ឌតំបន់។
- ភាគីទាំងពីរឯកភាពបន្តធ្វើការរួមគ្នា ក្នុងកិច្ចការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសកម្ពុជា ដោយសហភាពអឺរ៉ុបបានបញ្ជាក់អំពីការត្រៀមបង្កើនថវិកាជំនួយដល់ទៅ ២២ លានអឺរ៉ូ ទៅលើកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្តសម្រាប់ឆ្នាំ២០១៨។
- សហភាពអឺរ៉ុប បានគូសបញ្ជាក់អំពីការត្រៀមបង្កើនមូលនិធិជំនួយសម្រាប់កម្មវិធីវិនិយោគពីរ គឺ គម្រោងផ្គត់ផ្គង់ទឹកចំនួន ៥ លានអឺរ៉ូ និងគម្រោងជាពសាស្ត្រចំនួន ១១,៥ លានអឺរ៉ូ ដែលគម្រោងទាំងនេះជាចំណែកនៃកម្ចីចម្រុះចំនួន ១៣០ លានអឺរ៉ូ ផ្តល់ឲ្យតាមរយៈស្ថាប័នហិរញ្ញវត្ថុនានា។
- សហភាពអឺរ៉ុប សន្យាស្វែងរកប្រភពជំនួយផ្សេងទៀត ដើម្បីជួយក្រសួងពាណិជ្ជកម្មកម្ពុជា ក្នុងការអនុវត្តសកម្មភាពអាទិភាពក្នុងវិស័យគោលនយោបាយពាណិជ្ជកម្ម យុទ្ធសាស្ត្រនៃការចាកចេញពីឋានៈនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច និងការកែទម្រង់ច្បាប់។
- ភាគីទាំងពីរ ឯកភាពធ្វើការរួមគ្នាដើម្បីពន្លឿនការចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសម្រាប់កិច្ចសន្យាភាពជាដៃគូ និងកំណែទម្រង់វិស័យអប់រំ ដែលមានចំនួនទឹកប្រាក់សរុប ១០០ លានអឺរ៉ូ ហើយនេះជាគម្រោងជំនួយដ៏ធំបំផុតរបស់សហភាពអឺរ៉ុបផ្តល់ដល់វិស័យអប់រំកម្ពុជា។
- ក្នុងកិច្ចការកំណែទម្រង់វិមជ្ឈការថ្នាក់ក្រោមជាតិ ភាគីទាំងពីរទទួលស្គាល់ពីការរីកចម្រើនក្នុងកិច្ចការកំណែទម្រង់នេះ ក៏ប៉ុន្តែសហភាពអឺរ៉ុបបានសម្តែងការសោកស្តាយចំពោះស្ថានការណ៍នយោបាយនៅកម្ពុជា ដែលបានធ្វើឲ្យបាត់បង់អាសនៈក្រុមប្រឹក្សាឃុំសង្កាត់របស់គណបក្សប្រឆាំងជាង ៥០០០ តាមរយៈសាលក្រមរបស់តុលាការកម្ពុជាដែលបានសម្រេចរំលាយគណបក្សប្រឆាំង។ ការគាំទ្ររបស់សហភាពអឺរ៉ុបលើកិច្ចការនេះ កំពុងត្រូវបានពិនិត្យមើលឡើងវិញ (កាលពីឆ្នាំ២០១៧ សហភាពអឺរ៉ុបបានសម្រេចព្យួរជំនួយ ៧ លានអឺរ៉ូ ក្នុងវិស័យនេះ)។
- កម្ពុជា និងសហភាពអឺរ៉ុប ទទួលស្គាល់នូវវឌ្ឍនភាពដែលស្តែងចេញតាមរយៈលទ្ធផលការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០១៧ កន្លងទៅ រៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ កម្ពុជាបានស្នើសុំឲ្យសហភាពអឺរ៉ុប បន្តផ្តល់ជំនួយឡើងវិញដល់ គ.ជ.ប បន្ទាប់ពីបានសម្រេចពន្យារការផ្តល់ជំនួយកាលពីខែធ្នូ ឆ្នាំ២០១៧ និងបានបញ្ជាក់ថា កម្ពុជាស្វាគមន៍ប្រសិនបើសហភាពអឺរ៉ុប ពិចារណាចង់បញ្ជូនអ្នកសង្កេតការណ៍មកចូលរួមតាមដានដំណើរការបោះឆ្នោតសកល នៅក្នុងខែកក្កដា ឆ្នាំ២០១៨ នេះ។

- សហភាពអឺរ៉ុប បានបញ្ជាក់អំពីការបន្តផ្តល់ជំនួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ឆ្នាំ២០១៨-២០១៩ ដោយបានសង្កត់ធ្ងន់ថា ខ្លួននឹងខិតខំស្វែងរកមូលនិធិពីប្រភពផ្សេងៗទៀត ដើម្បីជួយគាំទ្រដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនេះ។
- កម្ពុជា និងសហភាពអឺរ៉ុប បានបញ្ជាក់ជាថ្មីថា ដំណើរការរៀបចំកម្មវិធីរួមរបស់សហភាពអឺរ៉ុបនៅកម្ពុជា ដែលរៀបចំជាក្រុមដៃគូរបស់សហភាពអឺរ៉ុបចំនួន១១ នឹងបន្តបង្ហាញអំពីលទ្ធផលល្អក្នុងការគាំទ្រប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់កម្ពុជា។ ភាគីទាំងពីរឯកភាពបន្តធ្វើការរួមគ្នាឲ្យបានជិតស្និទ្ធ ក្នុងការពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ភាគីទាំងពីរ បានគូសបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅ ធ្វើយ៉ាងណាប្រែក្លាយប្រទេសកម្ពុជា ឲ្យទៅជាប្រទេសមានប្រាក់ចំណូលកម្រិតមធ្យម ស្របតាមគោលដៅនៃរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ។

II. <u>អំពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ អភិបាលកិច្ច និងសិទ្ធិមនុស្ស</u>

- ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមក ដោយគណៈប្រតិភូកម្ពុជាបានខិតខំពន្យល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ជំរុញកំណែទម្រង់និងពង្រឹងប្រព័ន្ធច្បាប់ និងតុលាការ លើកស្ទួយសិទ្ធិស្ត្រីនិងកុមារ ពង្រឹងកិច្ចសហការជាមួយសង្គមស៊ីវិល ការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយ ការងាររៀបចំការបោះឆ្នោតសកលឆ្នាំ២០១៨ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសិទ្ធិការងារ និងដំណោះស្រាយដីសម្បទានសេដ្ឋកិច្ចនិងសង្គមកិច្ច ជាពិសេសដំណោះស្រាយលើករណីដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំស្ករអំពៅ។
- ភាគីកម្ពុជាបានបំភ្លឺ ដោយលើកឡើងនូវទឡ្ហីករណ៍ ហេតុផលទូលំទូលាយគ្រប់ជ្រុងជ្រោយនិងបញ្ជាក់អំពីវិធានការស្របច្បាប់របស់រាជរដ្ឋាភិបាល ក៏ដូចជានីតិវិធី និងសេចក្តីសម្រេចរបស់តុលាការ ជូនដល់ភាគីសហភាពអឺរ៉ុប បានជ្រាបក្នុងបរិការណ៍កម្ពុជា។
- សហភាពអឺរ៉ុប បានទទួលស្គាល់នូវវឌ្ឍនភាពក្នុងដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាល ប៉ុន្តែបានសម្តែងនូវការខកចិត្តនៃការធ្លាក់ចុះនៃដំណើរការប្រជាធិបតេយ្យ និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា ក្នុងដំណាក់កាលចុងក្រោយនេះ ហើយបន្តអំពាវនាវឲ្យរាជរដ្ឋាភិបាលចូលរួមពិភាក្សាប្រកបដោយស្ថាបនា ជាមួយគណបក្សប្រឆាំង និងចាត់វិធានការចាំបាច់នានាដើម្បីធានាបរិយាកាសនយោបាយដល់គណបក្សប្រឆាំង សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយអាចដំណើរការបានដោយសេរី។
- សហភាពអឺរ៉ុប បានអំពាវនាវឲ្យរាជរដ្ឋាភិបាល កែប្រែសេចក្តីសម្រេចចិត្តរបស់តុលាការកំពូលដោយដោះលែងបុគ្គល កឹម សុខា អនុញ្ញាតឲ្យសកម្មជនបក្សប្រឆាំងទាំង ១១៨ រូប អាចធ្វើសកម្មភាពនយោបាយឡើងវិញ និងអនុញ្ញាតឲ្យអតីតគណបក្សសង្គ្រោះជាតិ បានចូលរួមក្នុងការបោះឆ្នោតសកលខាងមុខ។
- សហភាពអឺរ៉ុប បានរំលឹកអំពីសេចក្តីសន្និដ្ឋានរបស់ក្រុមប្រឹក្សាអឺរ៉ុប ដែលបានអនុម័តដោយរដ្ឋមន្ត្រីការបរទេសសហភាពអឺរ៉ុប កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ដោយបានសម្រេចមិន

ផ្តល់ឱកាសគាំទ្រដំណើរការបោះឆ្នោតជាតិ ខែកក្កដា ឆ្នាំ២០១៨ និងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតនេះ បើលក្ខខណ្ឌខាងលើមិនមានដំណោះស្រាយ។

— ភាគីកម្ពុជាបានអះអាងជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការពង្រឹងបន្ថែមទៀតនូវនីតិរដ្ឋ និងរចនាសម្ព័ន្ធប្រជាធិបតេយ្យ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់កំណើនប្រកបដោយចីរភាព និងស្មើភាពដោយគ្មានការរើសអើងពីសង្គមធនធាន។

## III. អំពីពាណិជ្ជកម្ម និងការវិនិយោគ

— ភាគីទាំងពីរ បានពិភាក្សាពាក់ព័ន្ធនឹងការទទួលបានប្រព័ន្ធអនុគ្រោះពន្ធ «គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ» (Everything But Arms - EBA)។ សហភាពអឺរ៉ុបបានគូសបញ្ជាក់ពីជោគជ័យដ៏គួរឲ្យកត់សម្គាល់របស់កម្ពុជា ក្នុងការនាំចេញទំនិញទៅសហភាពអឺរ៉ុប និងការរួមចំណែកនៃយន្តការអនុគ្រោះពន្ធទូទៅលើកលែងតែអាវុធ ដែលជាកាតាលីករដ៏សំខាន់ សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។

— ទាក់ទងនឹងប្រព័ន្ធអនុគ្រោះពន្ធ EBA នេះ ភាគីទាំងពីរបានពិភាក្សាអំពីដីសម្បទានសេដ្ឋកិច្ចដំណាំស្ករអំពៅ សិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិនយោបាយ។ សហភាពអឺរ៉ុបបានសង្កត់ធ្ងន់លើដំណើរការប្រកបដោយតម្លាភាព និងពេញលេញ ដែលមានសារៈសំខាន់ក្នុងការផ្តល់សំណងដល់គ្រួសារដែលរងផលប៉ះពាល់ និងស្នើក្រសួងពាក់ព័ន្ធ បន្តជួយដោះស្រាយបញ្ហាទាំងនេះឲ្យបានឆាប់ ដើម្បីជៀសវាងការប៉ះពាល់លំហូរពាណិជ្ជកម្មកម្ពុជា ទៅកាន់ទីផ្សារសហភាពអឺរ៉ុប។

— ភាគីទាំងពីរបានពិភាក្សាពីច្រកទីផ្សារសម្រាប់ក្រុមហ៊ុនអឺរ៉ុបនៅកម្ពុជា និងបានពិនិត្យឡើងវិញនូវការរីកចម្រើនពាណិជ្ជកម្មនៅក្នុងវេទិកាតំបន់ និងពហុភាគី ដោយយល់អំពីសារៈសំខាន់នៃក្របខ័ណ្ឌវិនិយោគបើកទូលាយ និងសេរីនៅក្នុងប្រទេសកម្ពុជា ដើម្បីជំរុញឲ្យមានការវិនិយោគបន្ថែមពីសហភាពអឺរ៉ុបមកកាន់កម្ពុជា ក្នុងការគាំទ្រសង្វាក់តម្លៃក្នុងតំបន់ និងពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា។

— សហភាពអឺរ៉ុប បានប្រកាសបន្តលើកលែងការអនុវត្តបទបញ្ញត្តិអនុគ្រោះពន្ធ (derogation of preferential rules) របស់សហភាពអឺរ៉ុប សម្រាប់ឧស្សាហកម្មកង់ដែលផលិតនៅកម្ពុជា ហើយកម្ពុជាបានស្នើសហភាពអឺរ៉ុប ជួយជូនដំណឹងទៅអាជ្ញាធរម៉ាឡេស៊ីអំពីការបន្តលើកលែងឧស្សាហកម្មកង់នេះផងដែរ។

— ភាគីទាំងពីរ បានលើកឡើងអំពីការចាកចេញពីប្រទេសអភិវឌ្ឍតិចតួចរបស់កម្ពុជា និងការផ្លាស់ប្តូរទៅប្រព័ន្ធអនុគ្រោះពន្ធ GSP+។ សហភាពអឺរ៉ុប បានស្នើកម្ពុជាបន្តអនុវត្តគម្រោង GSP+ ក្នុងដំណាក់កាលអន្តរកាល ដើម្បីបំពេញនូវគម្លាតដែលអាចកើតមានមុននឹងកិច្ចព្រមព្រៀងតំបន់ និងតំបន់ អាចនឹងកើតឡើងនៅពេលអនាគត។

— សហភាពអឺរ៉ុប បានអបអរសាទរកម្ពុជាចំពោះការចូលរួមក្នុងកិច្ចព្រមព្រៀង ស្តីពីសុពលភាពប្រកាសនីយបត្រគតក្កកម្មរបស់សហភាពអឺរ៉ុប ដែលនឹងពង្រីកវិសាលភាពនៃប្រកាសនីយបត្រគតក្កកម្មអឺរ៉ុបមកក្នុងប្រទេសកម្ពុជា។

- កម្ពុជាបានបង្ហាញពីយុទ្ធសាស្ត្រសម្រាប់ពិពិធកម្មឧស្សាហកម្ម ដែលរួមបញ្ចូលទាំងការសម្របសម្រួលការវិនិយោគផងដែរ។ នៅក្នុងបរិបទនេះ ភាគីទាំងពីរក៏បានពិភាក្សាផងដែរ លើបទបញ្ញត្តិនានានៃសេចក្តីព្រាងច្បាប់នេះ ទាក់ទងនឹងការការពារអ្នកវិនិយោគ។
- ភាគីកម្ពុជា បានជូនដំណឹងអំពីការសម្រេចចិត្តរបស់ខ្លួនក្នុងការចូលរួមក្នុងប្រព័ន្ធស្វ័យវិញ្ញាបនប័ត្រ (REX) សម្រាប់អ្នកនាំចេញរបស់សហភាពអឺរ៉ុប នៅក្នុងឆ្នាំ២០១៩ ហើយបានស្នើសុំជំនួយបច្ចេកទេសបន្ថែមសម្រាប់ការអនុវត្តប្រព័ន្ធនេះ។ សហភាពអឺរ៉ុបក៏បានយល់ព្រមផងដែរចំពោះការសិក្សាស្វែងយល់ពីលទ្ធភាពសម្រាប់ការគាំទ្រ ក្រោមគម្រោង ARISE + Regional component ក្នុងខណៈដែលសហភាពអឺរ៉ុប នៅមិនទាន់បានចុះព្រមព្រៀងផ្នែកហិរញ្ញវត្ថុជាមួយ GIZ។
- ទាក់ទងនឹងការវិវឌ្ឍក្នុងតំបន់និងសកល ភាគីទាំងពីរយល់ស្របថា ទំនាក់ទំនងរវាងអាស៊ាន និងសហភាពអឺរ៉ុប មានភាពរឹងមាំ និងបានលើកឡើងពីគោលបំណងរួមក្នុងការបន្តកិច្ចចរចាពាណិជ្ជកម្មសេរីរវាងតំបន់ និងតំបន់។
- កម្ពុជាក៏បានសម្តែងនូវការព្រួយបារម្ភផងដែរ អំពីផលប៉ះពាល់មកលើប្រទេសកម្ពុជា តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនាពេលអនាគតរបស់សហភាពអឺរ៉ុប ជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ដូចជាវៀតណាម ដែលធ្វើឲ្យចុះខ្សោយប្រព័ន្ធអនុគ្រោះពន្ធ ដែលកម្ពុជាកំពុងទទួលបាន។ កម្ពុជាបានស្នើសុំជំនួយពីសហភាពអឺរ៉ុប ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ដែលអាចនឹងកើតមានលើការប្រកួតប្រជែងផ្នែកនាំចេញ ជាពិសេសដើម្បីជានាការផ្គត់ផ្គង់ដល់ធនធានឧស្សាហកម្មដែលកំពុងរីកចម្រើន តាមរយៈការប្រើប្រាស់ការពង្រីកវិធានបង្គុំសមាសភាព (extended cumulation)។

<u>សេចក្តីសន្និដ្ឋាន៖</u>

- ជារួម កិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យក្នុងបរិយាកាសយោគយល់ ស្និទ្ធស្នាល និងគោរពគ្នាទៅវិញទៅមក ដោយភាគីគណៈកម្មការអឺរ៉ុប (European Commission) បានបង្ហាញឲ្យឃើញពីការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការល្អជាមួយកម្ពុជា និងសមិទ្ធផលដែលសម្រេចបានកន្លងមក។ គណៈកម្មការអឺរ៉ុប បានគូសបញ្ជាក់ថា ការរីកចម្រើនរបស់ប្រទេសកម្ពុជា គឺជាជោគជ័យនៃការអនុវត្តជំនួយរបស់សហភាពអឺរ៉ុប ហើយបានប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា និងត្រៀមលក្ខណៈរៀបចំកម្មវិធីជំនួយនានា ឲ្យស៊ីសង្វាក់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដំណាក់កាលថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងរៀបចំដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ។
- បន្ទាប់ពីព្រឹត្តិការណ៍នយោបាយចុងក្រោយកាលពីចុងឆ្នាំ២០១៧ ដោយស្ថិតក្រោមសម្ពាធរបស់ក្រុមប្រឹក្សាអឺរ៉ុប (Council of the European Union) និងសភាអឺរ៉ុប (European Parliament) គណៈកម្មការអឺរ៉ុបបានសម្រេចព្យួរជំនួយមួយចំនួនដូចជា កម្មវិធីពង្រឹងប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (៧លានអឺរ៉ូ) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៤,៦៥លានអឺរ៉ូ) និងជំនួយដល់ គ.ជ.ប ។ ប៉ុន្តែនៅក្នុងកិច្ចប្រជុំនេះ គណៈកម្មការអឺរ៉ុបក៏បានប្រកាសបង្កើន និងពង្រីកជំនួយទៅផ្នែកផ្សេង ដែលធ្វើឲ្យទំហំជំនួយរបស់សហភាពអឺរ៉ុបនៅតែរក្សាបាន ក្នុងរង្វង់ ៤១០ លានអឺរ៉ូ តាមកម្មវិធីសូចនាករចម្រុះ (២០១៤-២០២០) របស់ខ្លួនដដែល។

- ទោះបីជាគណៈកម្មការអឺរ៉ុប ហាក់ដូចជាមានការយោគយល់អំពីសភាពការណ៍ពិតជាក់ស្តែងរបស់កម្ពុជា គណៈកម្មការអឺរ៉ុបនៅតែសម្តែងពីការព្រួយបារម្ភ និងបានស្នើរាជរដ្ឋាភិបាលកម្ពុជាខិតខំដោះស្រាយឲ្យបានឆាប់អំពី វិវាទដីសម្បទានសេដ្ឋកិច្ចដំណាំស្ករអំពៅ ការគោរពសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិនយោបាយ ដើម្បីបញ្ចៀសលទ្ធភាពនៃការដាក់ទណ្ឌកម្មរបស់សហភាពអឺរ៉ុប ទាក់ទងនឹងការដកប្រព័ន្ធអនុគ្រោះពន្ធ EBA ពីកម្ពុជា ដោយហេតុថា គណៈកម្មការអឺរ៉ុប កំពុងរងសម្ពាធយ៉ាងខ្លាំងពីក្រុមប្រឹក្សាអឺរ៉ុប និងសភាអឺរ៉ុប។ គណៈកម្មការអឺរ៉ុប ក៏បានទទួចស្នើរាជរដ្ឋាភិបាលពិចារណាបើកការចរចាជាមួយក្រុមប្រឆាំងផងដែរ។
- គណៈកម្មការអឺរ៉ុបបានគូសបញ្ជាក់ថា ខ្លួនត្រៀមជាស្រេចក្នុងការជួយដល់កម្ពុជា ដោយបានលើកឡើងថា «សូមមេត្តាជួយខ្ញុំ ដើម្បីឲ្យខ្ញុំអាចជួយអ្នក (Please help me to help you )»។
- ដោយឡែក «សេចក្តីប្រកាសព័ត៌មានរួមស្តីពីកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០» ត្រូវបានចរចាយ៉ាងស្វិតស្វាញ និងអស់ពេលជាច្រើនម៉ោង ដោយគណៈកម្មការអឺរ៉ុប បានទាមទាររំលេចវោហាស័ព្ទធ្ងន់ៗនៅក្នុងសេចក្តីប្រកាសព័ត៌មានរួម ដូចជា៖ ហៅស្ថានភាពប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជា ថាកំពុងបន្តធ្លាក់ដុនដាបជាខ្លាំង ចាត់ទុកស្ថានការវិវឌ្ឍន៍ចុងក្រោយនៅកម្ពុជា គឺជាដំណើរការប្រឆាំងនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ព្រមទាំងបានទាមទារឲ្យលុបចោលសាលក្រមតុលាការកំពូលដែលបានសម្រេចរំលាយគណបក្សប្រឆាំង និងដោះលែង លោក កឹម សុខា ជាដើម។ ប៉ុន្តែនៅចុងបញ្ចប់ គណៈកម្មការអឺរ៉ុប បានបន្ទន់ឥរិយាបទ និងយល់ព្រមដកចេញប្រយោគទាំងនេះចេញ សូម្បីតែឈ្មោះបុគ្គល កឹម សុខា និងឈ្មោះគណបក្សសង្គ្រោះជាតិ ក៏មិនត្រូវបានរំលេចក្នុងសេចក្តីប្រកាសព័ត៌មានរួមនេះឡើយ ហើយប្រការនេះ អាចបញ្ចៀសបាននូវការឆ្លៀតកេងចំណេញនយោបាយរបស់ពួកមជ្ឈដ្ឋានប្រឆាំង។
- សូមគោរពជូនភ្ជាប់ អត្ថបទបកប្រែ «សេចក្តីប្រកាសព័ត៌មានរួមស្តីពីកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០»។

សូម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាប និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ជាយថាហេតុ និងសូមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ប្រាក់ សុខុន

<u>ចម្លងជូន៖</u>
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល លេខ: 853
ថ្ងៃ 23.03.18 ម៉ោង........
បញ្ជូន:........

ថ្ងៃពុធ ៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

**សូមគោរពជូន**

**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុប លើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្សិក កាលពីថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០១៨។

**យោង ៖** - លិខិតអញ្ជើញលេខ៨៨៣សអ.កបទ.សអ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុប លើកទី១០ ដែលបានប្រព្រឹត្តទៅនៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្សិក កាលពីថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០១៨។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯកឧត្តម **លុយ ដាវីត** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានសមាជិកចំនួន ៣៩រូប តំណាងឲ្យក្រសួង និងស្ថាប័ន របស់រាជរដ្ឋាភិបាលចំនួន ១៦។ តំណាងក្រសួងមហាផ្ទៃមាន៥រូបគឺ៖

| | |
|---|---|
| ១- ខ្ញុំបាទ **ទី ច័ន្ទផល** | រដ្ឋលេខាធិការ |
| ២- ឯកឧត្តម **ខ៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ |
| ៣- ឯកឧត្តម **ហ៊ុយ វណ្ណៈ** | អនុរដ្ឋលេខាធិការ |
| ៤- លោកជំទាវ **វ៉ែន សិរីលក្ខិណា** | អគ្គលេខាធិការរង គ.ជ.ប.ជ. |
| ៥- លោកស្រី **ទី ច័ន្ទពុទ្ធិតា** | ជំនួយការឯកឧត្តមរដ្ឋលេខាធិការ |

កិច្ចប្រជុំបានដំណើរការអស់រយៈពេល០៣ថ្ងៃ និងបែងចែកកិច្ចពិភាក្សាជា៣អនុក្រុម ដឹកនាំដោយសហប្រធាន តំណាងឲ្យកម្ពុជា០១នាក់ និងសហភាពអឺរ៉ុប០១ គឺ៖

ទី១- អនុក្រុមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (ថ្ងៃទី១២មីនា២០១៨) ដឹកនាំដោយតំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសហប្រធាន។ ភាគីទាំងពីរបានពិនិត្យឡើងវិញអំពីការគាំទ្ររបស់សហភាពអឺរ៉ុបចំពោះកម្មវិធីកំណែទម្រង់ និងផែនការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងអនុក្រុមនេះ ឯកឧត្តម **ម៉ាន់ ចំរើន** បានធ្វើបទអន្តរាគមន៍លើប្រធានបទ *"ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"* តំណាងឲ្យក្រសួងមហាផ្ទៃ ។

ទី២- អនុក្រុមស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ អភិបាលកិច្ច និងសិទ្ធិមនុស្ស (ថ្ងៃទី១៣មីនា២០១៨) ដឹកនាំកិច្ចប្រជុំដោយ ខ្ញុំបាទ **ទី ច័ន្ទ្រផល** តំណាងកម្ពុជា ជាសហប្រធាន។ ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរទស្សនៈគ្នាលើវឌ្ឍនភាព និងការប្រឈមមួយចំនួនដូចជា សេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយ អំពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ កំណែទម្រង់ការពង្រឹងប្រព័ន្ធច្បាប់ និងតុលាការ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការពង្រឹងសង្គមស៊ីវិល ដំណោះស្រាយដីសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច ជាពិសេសដំណោះស្រាយលើករណីដីដំណាំចំការអំពៅ និងសិទ្ធការងារជាដើម។ ចំពោះករណីនេះសហភាពអឺរ៉ុបបានទទួលស្គាល់នូវការរីកចំរើនក្នុងដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាល ក៏ប៉ុន្តែក៏បានសំដែងនូវការខកចិត្តចំពោះការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាក្នុងដំណាក់កាលចុងក្រោយនេះ។ តំណាងភាគីសហភាពអឺរ៉ុប បានស្នើសុំឲ្យរាជរដ្ឋាភិបាលកែប្រែសេចក្តីសម្រេចចិត្តរបស់តុលាការកំពូលដោយត្រូវដោះលែងបុគ្គល កឹម សុខា ចេញពីមន្ទីរឃុំឃាំង អនុញ្ញាតឲ្យសកម្មជន១១៨រូប អាចធ្វើសកម្មភាពនយោបាយឡើងវិញ និងអនុញ្ញាតឲ្យអតីតគណបក្សសង្គ្រោះជាតិ បានចូលរួមការបោះឆ្នោតខាងមុខ។ ភាគីកម្ពុជា ក៏បានលើកបំភ្លឺពីទឡ្ហីករណ៍ ពីហេតុផលយ៉ាងទូលំទូលាយគ្រប់ជ្រុងជ្រោយ និងវិធានការស្របច្បាប់របស់រាជរដ្ឋាភិបាលជូនដល់ភាគីសហភាពអឺរ៉ុប បានជ្រាបក្នុងបរិការណ៍កម្ពុជា។ ភាគីសហភាពអឺរ៉ុប បានអំពាវនាវជាថ្មីម្តងទៀត ឲ្យរាជរដ្ឋាភិបាលកម្ពុជា ចូលរួមពិភាក្សាដោយស្ថាបនា ជាមួយគណបក្សប្រឆាំង និងចាត់វិធានការចាំបាច់ដើម្បីធានាឲ្យបរិយាកាសនយោបាយមួយដែលគណបក្សប្រឆាំង សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ អាចដំណើការបានដោយសេរី។ តំណាងរាជរដ្ឋាភិបាល បានបញ្ជាក់ពីការប្តេជ្ញាពង្រឹងបន្ថែមទៀត នូវនីតិរដ្ឋ និងរចនាសម្ព័ន្ធប្រជាធិបេតយ្យ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយចីរភាព និងស្មើភាពដោយគ្មានការរើសអើងជ្រៀតជ្រែកពីបរទេស។ ភាគីសហភាពអឺរ៉ុបក៏បានស្នើឲ្យរាជរដ្ឋាភិបាល ខិតខំដោះស្រាយបញ្ចប់ករណីវិវាទដីសម្បទានសេដ្ឋកិច្ច ដំណាំអំពៅដែលនៅសេសសល់(សមត្ថកិច្ចក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងពាណិជ្ជកម្ម)។ ភាគីសហភាពអឺរ៉ុបបានលើកឡើងពីការសម្រេចចិត្តមិនផ្តល់ថវិកា និងមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតខាងមុខ បើលក្ខខណ្ឌខាងលើមិនមានដំណោះស្រាយ។

ក្នុងកិច្ចប្រជុំអនុក្រុមនេះ ប្រតិភូតំណាងក្រសួងមហាផ្ទៃ បានធ្វើបទអន្តរាគមន៍ដូចខាងក្រោម៖

១- ខ្ញុំបាទ **ទី ច័ន្ទ្រផល** ជាសហប្រធានដឹកនាំកិច្ចប្រជុំអនុក្រុម និងបានធ្វើបទអន្តរាគមន៍លើប្រធានបទស្តីពី - *"ស្ថានភាពសង្គមស៊ីវិល និងការអនុវត្តច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"* ។
២- ឯកឧត្តម **ហ៊ុយ ចណ្ណា** បានធ្វើបទអន្តរាគមន៍ ស្តីពី *"សិទ្ធិនយោបាយ និងលទ្ធិប្រជាធិបតេយ្យ"* ។
៣- លោកជំទាវ **រ៉ែន សិរីលក្ខិណា** បានធ្វើបទអន្តរាគមន៍ ស្តីពី *"បច្ចុប្បន្នភាព ការខិតខំ និងវឌ្ឍនភាពលើការទប់ស្កាត់ការជួញដូរមនុស្សនៅកម្ពុជា"*។

ទី៣- កិច្ចប្រជុំអនុក្រុមស្តីពីពាណិជ្ជកម្ម និងវិនិយោគ (ថ្ងៃទី១៣មីនា២០១៨) ដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ជាសហប្រធាន និង បានពិនិត្យពិភាក្សាឡើងវិញពីស្ថានភាពពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-សហភាពអឺរ៉ុប និងបរិយាកាសវិនិយោគនៅកម្ពុជា។ ភាគីទាំងពីរបានដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការទទួលបានប្រព័ន្ធអនុគ្រោះពន្ធ "គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ" –"Everything But Arms (EBA)" ដែលបានជួយធ្វើឲ្យប្រសើរឡើងនូវពាណិជ្ជកម្មទ្វេភាគី និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជានាឆ្នាំកន្លងមកថ្មីៗនេះ។ ភាគីទាំងពីរក៏បានពិភាក្សាពីច្រកទីផ្សារសម្រាប់ក្រុមហ៊ុនអឺរ៉ុបនៅកម្ពុជា និងបានពិនិត្យឡើងវិញនូវការរីកចំរើន ពាណិជ្ជកម្មនៅក្នុងតំបន់ និងពហុភាគី។

ទី៤- កិច្ចប្រជុំរួមរបស់គណៈកម្មាធិការចំរុះ (ថ្ងៃទី១៤មីនា២០១៨) ដឹកនាំដោយ តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសហប្រធាន ដើម្បីធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំតាមអនុក្រុមនីមួយៗ និង បានលើកឡើងពីទស្សនៈរៀងៗខ្លួនលើបញ្ហានយោបាយ ការងារបោះឆ្នោតឆ្នាំ២០១៨ ការងារអភិបាលកិច្ច និងសិទ្ធិមនុស្ស បញ្ហាដីធ្លី និងការគ្រប់គ្រងបរិស្ថាន និងបញ្ហាទំនាក់ទំនងពហុភាគី និងបញ្ហាក្នុងតំបន់មួយចំនួន។ ក្នុងកិច្ចប្រជុំរួមនេះ ក្នុងនាមក្រសួងមហាផ្ទៃខ្ញុំបាទ **ឌី ច័ន្ទផល** បានធ្វើបទអន្តរាគមន៍លើប្រធានបទស្តី *"អភិបាលកិច្ច និងសិទ្ធិមនុស្ស"* - និង *"ស្ថានភាពទេសន្តប្រវេសន៍នៅកម្ពុជា"* ។

បន្ទាប់ពីកិច្ចប្រជុំរួម ភាគីទាំងពីរបានឯកភាពចេញនូវ "សេចក្តីប្រកាសព័ត៌មានរួម" នៃកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ ជាភាសាអង់គ្លេស និងបានបកប្រែជាភាសាខ្មែរ(ក្រៅផ្លូវការ) ដូចបានជូនភ្ជាប់។ ដោយឡែក កំណត់ហេតុនៃកិច្ចប្រជុំកំពុងត្រូវបានរៀបចំឡើងដោយភាគីទាំងពីរ ហើយនឹងត្រូវបានផ្លាស់ប្តូរគ្នាជាផ្លូវការបន្ទាប់ពីមានការឯកភាពគ្នាហើយ ។

អាស្រ័យហេតុនេះសូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**រដ្ឋលេខាធិការ**

**ឌី ច័ន្ទផល**

**ឯកសារជូនភ្ជាប់៖**

- សេចក្តីប្រកាសរួម (ភាសាអង់គ្លេស) ០១ច្បាប់
- សេចក្តីប្រកាសរួម (ភាសាខ្មែរ បកប្រែក្រៅផ្លូវការ) ០១ច្បាប់

## Joint Press Release: European Union and Cambodia hold 10th Joint Committee Meeting

Brussels, 14 March 2018

The 10th EU-Cambodia Joint Committee Meeting was held in Brussels on 14 March 2018 and was preceded by subgroups on development cooperation, and on institution building, administrative reform, legal and judicial reform, governance and human rights, and on trade and Investment.

The EU welcomed and praised Cambodia's progress and achievement in socio-economic rights and valued the good cooperation with Cambodia over the past two decades. The EU and Cambodia reaffirmed their commitment to deepen their relationship and cooperation based on the principles of equality, mutual respect and open dialogue and by promoting the implementation of the objectives set out in the 1997 Cambodia-EU Cooperation Agreement.

The meeting allowed for an exchange of views on a broad range of bilateral issues, including current political development in Cambodia and the EU, multilateral and regional issues such as the Mekong Sub-region, EU-ASEAN relations, climate change and human rights cooperation in UN fora.

The European Union presented the Council Conclusions adopted by the EU Foreign Affairs Ministers on 26 February 2018 in which the EU expressed serious concerns about recent developments regarding democracy, respect for human rights and the rule of law in Cambodia. In response, Cambodia recalled that recent development in Cambodia are actions of the competent authorities and the judiciary organs to enforce rule of laws, protect its sovereignty and maintain the core interest of peace and stability of Cambodia for a harmonious society and the continued sustainable development. Cambodia reiterated its commitment to uphold the pluralistic society and respect of fundamental freedom and human rights as enshrined in Cambodia's Constitution and relevant laws. Cambodia reaffirmed its commitment to conduct the general election on 29 July 2018 in an orderly, smooth, free, fair and peaceful manner.

The Cooperation Committee reviewed the outcomes of the three sub-groups that were held in the run up to the Committee meeting.

In the sub-group on Development Cooperation, held on 12 March, the two sides reviewed the EU's support to the Royal Government's reform programmes and its plans to implement the Sustainable Development Goals. EU development cooperation is closely aligned to the Royal Government's Rectangular Strategy and its sectoral reform programmes. The EU will continue to assess its development cooperation programmes with a view to ensuring the strengthening of democratic principles, respect for human rights and the rule of law. Cooperation focusses on three sectors - agriculture and natural resources management; education; and governance and administration (including support to public financial management and decentralisation). Thematic and regional programmes in areas such as environment, climate change, trade related assistance and human rights were also discussed, as well as EU support for the Extraordinary Chambers in the Courts of Cambodia.

The sub-group on Institution Building, Administrative Reform, Legal Reform, Governance and Human Rights on 13 March discussed and exchanged views on progress and challenges on issues such as freedom of expression and the media, the fight against corruption, economic land concession for sugar plantations, strengthening of civil society, the rights of women and children, and labour rights. The EU reiterated its call on the Cambodian Government to engage in a constructive dialogue with the opposition and to take all necessary measure to ensure a political environment in which opposition parties, civil society and media can operate freely. The Cambodian government affirmed its commitment to further strengthen the rule of law and democratic structures as an underpinning for sustainable and equitable growth free from any foreign interference.

The sub-group on Trade and Investment, also held on 13 March, reviewed EU-Cambodia bilateral trade and the investment climate in Cambodia. Bilateral trade was over €5 billion in 2017 (UNCOMTrade Data). The two parties addressed a number of issues in relation to the uptake of the 'Everything But Arms' arrangement which has helped improve bilateral trade and contribute Cambodia's impressive economic growth over recent years. Furthermore, the parties discussed market access for European companies in Cambodia and reviewed trade developments in regional and multilateral fora. The two sides agreed on the importance of an open and liberalized investment framework in Cambodia to encourage further investment from the EU to Cambodia to support regional value chains and Cambodia's economic diversification. The EU congratulated Cambodia for joining the EU Patent Validation Agreement extending the coverage of European patents to Cambodia and the deposit of the instrument of ratification of the Geneva Act of the Lisbon Agreement on Appellations of Origin and Geographical Indications to the World Intellectual Property Organization (WIPO). The EU recalled that the respect of human rights and fundamental freedoms, including labour rights, underpins the continued eligibility for EU trade preferences under the EBA for LDCs. The EU expressed its concerns in particular on the issue related to Economic Land Concession for Sugar Plantation, human rights and labour issues and that urgent action on the Cambodian side is needed to address these issues.

The Joint Committee was co-chaired by Ms. Paola Pampaloni, Deputy Managing Director Asia and Pacific of the European External Action Service (EEAS) and Mr. Luy David, Secretary of State of the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia.

It was agreed to hold the 11$^{th}$ Cambodia-EU Joint Committee and its three Sub-group meetings in 2020 in Cambodia.

(អត្ថបទបកប្រែក្រៅផ្លូវការ)

## សេចក្តីប្រកាសព័ត៌មានរួម
## កិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០

ប្រ៊ុចសែល ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨

កិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-អឺរ៉ុបលើកទី១០ ត្រូវបានប្រារព្ធធ្វើនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ នៅទីក្រុងប្រ៊ុចសែល ដែលត្រូវបាននាំមុខដោយកិច្ចប្រជុំអនុក្រុមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ អនុក្រុមស្តីពីការកសាងស្ថាប័ន កំណែទំរង់រដ្ឋបាល កំណែទំរង់ច្បាប់និងតុលាការ អភិបាលកិច្ច និងសិទ្ធិមនុស្ស ហើយនិងអនុក្រុមស្តីពីពាណិជ្ជកម្ម និងការវិនិយោគ។

សហភាពអឺរ៉ុប បានស្វាគមន៍ និងកោតសរសើរចំពោះការរីកចំរើន និងសមិទ្ធិផលពាក់ព័ន្ធនឹងសិទ្ធិសេដ្ឋកិច្ចសង្គមរបស់កម្ពុជា និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយកម្ពុជា ក្នុងរយៈកាលជាងពីរទសវត្សន៍កន្លងមកនេះ។ កម្ពុជា និងសហភាពអឺរ៉ុបបានអះអាងឡើងវិញនូវការប្តេជ្ញារបស់ខ្លួនក្នុងការធ្វើឲ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅ ឈរលើគោលការណ៍សមភាព ការគោរពគ្នាទៅវិញទៅមក និងការសន្ទនាបើកទូលាយ ហើយនិងតាមរយៈការលើកកម្ពស់ការអនុវត្តនូវគោលដៅ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងសហប្រតិបត្តិការកម្ពុជា-សហភាពអឺរ៉ុបឆ្នាំ១៩៩៧។

ក្នុងកិច្ចប្រជុំនេះ មានការផ្លាស់ប្តូរទស្សនៈលើបញ្ហាទ្វេភាគីជាច្រើន រួមទាំងការវិវឌ្ឍផ្នែកនយោបាយនាពេលបច្ចុប្បន្ននៅកម្ពុជា និងនៅសហភាពអឺរ៉ុប បញ្ហាតំបន់ និងពហុភាគី ដូចជាអនុតំបន់ទន្លេមេគង្គ ទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប ការប្រែប្រួលអាកាសធាតុ និងកិច្ចសហប្រតិបត្តិការលើវិស័យសិទ្ធិមនុស្សក្នុងវេទិកាអង្គការសហប្រជាជាតិនានា។

សហភាពអឺរ៉ុប បានបង្ហាញអំពីសេចក្តីសន្និដ្ឋានរបស់ក្រុមប្រឹក្សាកិច្ចការបរទេសសហភាពអឺរ៉ុប ដែលបានអនុម័តដោយរដ្ឋមន្ត្រីការបរទេសរបស់សហភាពអឺរ៉ុប កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលក្នុងនោះសហភាពអឺរ៉ុបបានសំដែងពីការព្រួយបារម្ភណ៍ចំពោះការវិវឌ្ឍថ្មីៗទាក់ទងនឹងប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋនៅកម្ពុជា។ ជាកិច្ចឆ្លើយតប កម្ពុជាបានរំលឹកឡើងវិញថា ការវិវឌ្ឍថ្មីៗនៅក្នុងប្រទេសកម្ពុជា គឺជាចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ដើម្បីពង្រឹងនីតិរដ្ឋ ការពារអធិបតេយ្យភាពរបស់ខ្លួន និងរក្សានូវផលប្រយោជន៍ស្នូលនៃសន្តិភាព និងស្ថិរភាពរបស់កម្ពុជា ដើម្បីឲ្យសង្គមមានភាពសុខដុមរមនា និងការអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាបានអះអាងជាថ្មីពីការប្តេជ្ញាប្រកាន់ខ្ជាប់សង្គមពហុបក្ស និងការគោរពសេរីភាពជាមូលដ្ឋាន និងសិទ្ធិមនុស្ស ដូចដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការរៀបចំការបោះឆ្នោតសកលនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រកបដោយសណ្តាប់ធ្នាប់ រលូន សេរី យុត្តិធម៌ និងសន្តិវិធី។

គណៈកម្មាធិការកិច្ចសហប្រតិបត្តិការ បានពិនិត្យឡើងវិញនូវលទ្ធផលនៃកិច្ចប្រជុំអនុក្រុមទាំងបី ដែលបានធ្វើឡើងនៅមុនកិច្ចប្រជុំគណៈកម្មាធិការចំរុះ។

នៅក្នុងកិច្ចប្រជុំអនុក្រុមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ នៅថ្ងៃទី១២ ខែមីនា ភាគីទាំងពីរបាន ពិនិត្យឡើងវិញអំពីការគាំទ្ររបស់សហភាពអឺរ៉ុបចំពោះកម្មវិធីកំណែទម្រង់ និងផែនការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប បានភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងយុទ្ធសាស្ត្រចតុកោណ និងកម្មវិធីកំណែទម្រង់វិស័យនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ សហភាពអឺរ៉ុបនឹងបន្តវាយតម្លៃកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគោលការណ៍ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ កិច្ចសហប្រតិបត្តិការនេះ ផ្តោតលើវិស័យចំនួនបីគឺ កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ អប់រំ អភិបាលកិច្ច និងរដ្ឋបាល (រួមទាំងការគាំទ្រការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការ)។ កម្មវិធីក្នុងតំបន់ និងតាមវិស័យ ដូចជាបរិស្ថាន ការប្រែប្រួលអាកាសធាតុ ជំនួយទាក់ទងនឹងពាណិជ្ជកម្ម និងសិទ្ធិមនុស្ស ក៏ត្រូវបានលើកយកមកពិភាក្សា ព្រមទាំងការគាំទ្ររបស់សហភាពអឺរ៉ុប ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

កិច្ចប្រជុំអនុក្រុមស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ អភិបាលកិច្ច និងសិទ្ធិមនុស្ស នៅថ្ងៃទី១៣ ខែមីនា បានពិភាក្សាផ្លាស់ប្តូរទស្សនៈគ្នាលើវឌ្ឍនភាព និងបញ្ហាប្រឈមមួយចំនួនដូចជា សេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធឃោសនា ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំស្កអំពៅ ការពង្រឹងសង្គមស៊ីវិល សិទ្ធិស្ត្រី និងកុមារ និងសិទ្ធិការងារ។ សហភាពអឺរ៉ុបបានអំពាវនាវជាថ្មីម្តងទៀត ឲ្យរាជរដ្ឋាភិបាលកម្ពុជា ចូលរួមពិភាក្សាប្រកបដោយស្ថាបនា ជាមួយគណបក្សប្រឆាំង និងចាត់វិធានការចាំបាច់ដើម្បីធានាបរិយាកាសនយោបាយមួយ ដែលគណបក្សប្រឆាំង សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ អាចដំណើរការបានដោយសេរី។ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ពីការប្តេជ្ញាពង្រឹងបន្ថែមទៀតនូវនីតិរដ្ឋ និងរចនាសម្ព័ន្ធប្រជាធិបតេយ្យ ដែលជាមូលដ្ឋានសម្រាប់ទ្រទ្រង់កំណើនប្រកបដោយចីរភាព និងស្មើភាព ដោយគ្មានការជ្រៀតជ្រែកពីបរទេស។

កិច្ចប្រជុំអនុក្រុមស្តីពីពាណិជ្ជកម្ម និងវិនិយោគ នៅថ្ងៃទី១៣ ខែមីនានេះដែរ បានពិនិត្យឡើងវិញនូវពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-សហភាពអឺរ៉ុប និងបរិយាកាសវិនិយោគនៅកម្ពុជា។ ទំហំពាណិជ្ជកម្មទ្វេភាគីមានចំនួនជាង ៥ពាន់លានអឺរ៉ូ ក្នុងឆ្នាំ២០១៧ (ប្រភព៖ UNCOM Trade Data)។ ភាគីទាំងពីរបានដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការទទួលបានប្រព័ន្ធអនុគ្រោះពន្ធ «គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ - Everything But Arms (EBA)» ដែលបានជួយធ្វើឲ្យប្រសើរឡើងនូវពាណិជ្ជកម្មទ្វេភាគី និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចគួរឲ្យចាប់អារម្មណ៍របស់កម្ពុជា នៅក្នុងឆ្នាំកន្លងមកថ្មីៗនេះ។ លើសពីនេះទៀត ភាគីទាំងពីរបានពិភាក្សាពីប្រកទីផ្សារសម្រាប់ក្រុមហ៊ុនអឺរ៉ុប នៅកម្ពុជា និងបានពិនិត្យឡើងវិញនូវការរីកចំរើនពាណិជ្ជកម្មនៅក្នុងវេទិកាតំបន់ និងពហុភាគី។ ភាគីទាំងពីរបានយល់ស្របគ្នាពីសារៈសំខាន់នៃក្របខ័ណ្ឌវិនិយោគបើកទូលាយ និងសេរីនៅក្នុងប្រទេសកម្ពុជា ដើម្បីជំរុញឲ្យមានការវិនិយោគបន្ថែមពី

សហភាពអឺរ៉ុបមកកាន់កម្ពុជា ក្នុងការគាំទ្រដល់សង្វាក់តម្លៃក្នុងតំបន់ និងពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា។ សហភាពអឺរ៉ុប បានអបអរសាទរកម្ពុជា ដែលបានចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីការផ្តល់សុពលភាពដល់ប្រកាសនីយប័ត្រតក្កកម្មរបស់សហភាពអឺរ៉ុប ដែលបានពង្រីកការគ្របដណ្តប់របស់ប្រកាសនីយប័ត្រតក្កកម្មរបស់សហភាពអឺរ៉ុបដល់កម្ពុជា និងការតំកល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញាទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសបោន ស្តីពីឈ្មោះប្រភពដើមទំនិញ និងម៉ាកសំគាល់ភូមិសាស្ត្រទំនិញនៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។ សហភាពអឺរ៉ុបបានរំលឹកថា ការគោរពសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗ រួមទាំងសិទ្ធិការងារ គឺជាមូលដ្ឋានដើម្បីបន្តទទួលបាននូវប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបក្រោមប្រព័ន្ធ EBA សម្រាប់ប្រទេសអភិវឌ្ឍតិចតួច។ សហភាពអឺរ៉ុប បានសម្តែងការព្រួយបារម្ភចំពោះបញ្ហាដីសម្បទានសេដ្ឋកិច្ចដំណាំស្ករអំពៅ សិទ្ធិមនុស្ស និងបញ្ហាការងារ ហើយស្នើកម្ពុជាចាត់វិធានការបន្ទាន់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

កិច្ចប្រជុំគណៈកម្មាធិការចំរុះនេះ ដឹកនាំជាសហប្រធានដោយ**ឯកឧត្តម លុយ ដាវីត** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រី **ប៉ៅឡា ផាមផាឡូនី** (Paola Pampaloni) អនុប្រធាននាយកដ្ឋានកិច្ចការអាស៊ី និងប៉ាស៊ីហ្វិក នៃមន្ទីរការបរទេសរបស់សហភាពអឺរ៉ុប។

អង្គប្រជុំបានឯកភាពគ្នារៀបចំកិច្ចប្រជុំគណៈកម្មាធិការចំរុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១១ និងកិច្ចប្រជុំអនុក្រុមទាំងបី នៅឆ្នាំ២០២០ នៅប្រទេសកម្ពុជា។

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា លើការចេញផ្សាយរបាយការណ៍សំយោគប្រចាំឆ្នាំ លើកទី៣៤ ស្តីពីលក្ខខណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា

១/ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មការប្រឹក្សាគម្រោងរបស់អង្គការអន្តរជាតិខាងការងារនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា បានជួបប្រជុំនៅទីក្រុងភ្នំពេញដើម្បីពិនិត្យរបាយការណ៍សំយោគលើកទី៣៤ស្តីពីលក្ខខណ្ឌការងារក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា។ គណៈកម្មការប្រឹក្សាគម្រោងមានសមាសភាពតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា (ក្រសួងការងារ និងបណ្តុះបណ្តាលជីវៈ និងក្រសួងពាណិជ្ជកម្ម) និយោជក (សមាគមរោងចក្រ កាត់ដេរនៅកម្ពុជា) និងកម្មករនិយោជិត (តំណាងមកពីសហភាព និងសហព័ន្ធផ្សេងៗ) ។

២/ យើងខ្ញុំដែលជាសមាជិកគណៈកម្មការប្រឹក្សាគម្រោង សូមស្វាគមន៍ទៅនឹងការចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំនេះ ដែលបង្ហាញព័តិមានស្តីពីភាពអនុលោមតាមច្បាប់ ដោយផ្អែកលើការរកឃើញនៃការវាយតម្លៃរោងចក្រចំនួន៣៩៥ ដែលធ្វើឡើងដោយ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ចន្លោះពីថ្ងៃទី០១ ខែឧសភាឆ្នាំ ២០១៦ ដល់ថ្ងៃទី៣០ ខែមេសាឆ្នាំ ២០១៧ ។

៣/ យើងពិតជារីករាយជាមួយនឹងលទ្ធផលដែលរកឃើញនៅក្នុងរបាយការណ៍នេះ ព្រោះវាបង្ហាញពីការថយចុះលើករណីកម្មករដែលមិនទាន់គ្រប់អាយុនៅក្នុងវិស័យនេះ ដូចជាកំណើនចំនួនរោងចក្រដែលបានអនុលោមទៅនឹងបញ្ហាចម្បងទាំង ២១ចំនុច ព្រមទាំងការថយចុះនូវចំនួនរំលោភបំពានលើករណីផ្សេងៗក្នុងចំណោមបញ្ហាចម្បងៗទាំង២១ ។

៤/ យើងបានកត់សំគាល់ផងដែរថា មានតម្រូវការឱ្យមានការយកចិត្តទុកដាក់ជាថ្មីឡើងវិញ លើបញ្ហាផ្សេងទៀត ដូចជាការត្រៀមក្នុងគ្រាមានអាសន្ន និងបញ្ហាស្តីពីសុខភាព និងសុវត្ថិភាពការងារ រួមមានការប្រើប្រាស់សារធាតុគីមី និងការការពារខ្លួន។ យើងសូមជំរុញអោយ **គម្រោងរោងចក្រកាន់តែប្រសើរកម្ពុជា** បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការគាំទ្រដល់រោងចក្រដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងឱ្យកាន់តែមានលក្ខណៈល្អប្រសើរជាងមុនក្នុងការលើកកម្ពស់គោលនយោបាយ និងការអនុវត្តន៍ដ៏រឹងមាំជុំវិញបញ្ហាសុខភាព និងសុវត្ថិភាពការងារ ព្រមទាំងការគ្រប់គ្រងធនធានមនុស្ស។ ទាំងនេះគឺជាការងារសំខាន់ក្នុងការបន្តជម្រុញការកែលម្អដែលប្រកបដោយនិរន្តរភាពនៅក្នុងវិស័យមួយនេះ ។


Better Factories Cambodia
No9, Street 322, Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642
www.betterwork.org

៥/ យើងទទួលស្គាល់ពីសារៈសំខាន់ និងគុណតម្លៃនៃគំនិតផ្តួចផ្តើមទាំងឡាយដែលមាននៅក្នុងវិស័យនេះដែលមានគោលបំណងធ្វើឱ្យប្រសើរឡើង នូវការអនុលោមតាមបទដ្ឋានការងារ ដូចជាការសហការគ្នាក្នុងការដោះស្រាយបញ្ហាពលកម្មកុមារ និងការ ចេញផ្សាយរបាយការណ៍ជាសាធារណៈរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅម្ពុជា ។ គំនិតផ្តួចផ្តើមទាំងនោះបានបង្ហាញអោយឃើញស្តីពីការអនុលោមតាមបទដ្ឋានការងារ និងលក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតព្រមទាំងជួយលើកស្ទួយកេរ្តិ៍ឈ្មោះនៃវិស័យនេះ ។ គណៈកម្មការប្រឹក្សាគម្រោង សូមស្វាគមន៍លើការពង្រឹងកិច្ចសហការព្រមទាំងបញ្ហានានដែលមិនអាចលើកលែងបាន និងចាំបាច់ត្រូវតែធ្វើការដោះស្រាយប្រកបដោយប្រសិទ្ធិភាពពាក់ព័ន្ធទៅនឹងករណីនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៅកន្លែងការងារ ។

៦/ យើងទទួលស្គាល់ថា សមាជិកគណៈកម្មការប្រឹក្សាគម្រោងនីមួយៗ មានទំនួលខុសត្រូវខ្ពស់សម្រាប់ធ្វើឱ្យវិស័យនេះមានភាពប្រសើរឡើងយ៉ាងខ្លាំង ។ ចំណុចទាំងនេះរួមមានៈ

ក. សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ត្រូវផ្តល់ការគាំទ្រទៅសមាជិករបស់ខ្លួនក្នុងការបង្កើតបរិយាកាសស្តីពីការងារដែលមានភាពអនុលោម ។

ខ. រាជរដ្ឋាភិបាលកម្ពុជាត្រូវប្រើប្រាស់យន្តការពង្រឹងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ ជាពិសេសនៅក្នុងរោងចក្រទាំងឡាយណាដែលមានភាពអនុលោមទាប ។

គ. សហជីពក៏មានតួនាទី និងការទទួលខុសត្រូវខ្ពស់ផងដែរ ក្នុងការជម្រុញដល់រោងចក្រទាំងអស់ឱ្យអនុលោមតាមបទដ្ឋានច្បាប់ការងារ ហើយជារួមគឺសហជីពមូលដ្ឋានគួរតែធ្វើការរួមគ្នាជាមួយនិយោជក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីការដោះស្រាយបញ្ហាទាំងឡាយដែលកើតមានឡើង ។ ភាពចាស់ទុំនៃទំនាក់ទំនងវិជ្ជាជីវៈគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ដែលរួមចំណែកធ្វើឱ្យលក្ខខណ្ឌការងារកាន់តែប្រសើរឡើង ។

ជាលទ្ធផលរួម យើងអាចសន្និដ្ឋានបានថាកិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ដែលជាយុទ្ធសាស្ត្រចាំបាច់នាពេលអនាគតរបស់វិស័យមួយនេះ ក្នុងនោះវាក៏ពាក់ព័ន្ធទៅនឹងជីវភាព និងការរស់នៅរបស់កម្មករនិយោជិតរាប់សែននាក់ក្នុងវិស័យកាត់ដេរនៅក្នុងប្រទេសកម្ពុជា រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេក៏ដូចជាការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលផងដែរ ។

